សុន្ទរកថារបស់ **ឯកឧត្តម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា**

ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន

**២៩ មិថុនា ២០១៧**

- សូមគោរព លោកស្រី SONODA Tomoko នាយិកាការិយាល័យភ្នំពេញនៃអង្គការAARជប៉ុន
- សូមគោរព អស់លោក លោកស្រី!

ថ្ងៃនេះខ្ញុំមានសេចក្តីសប្បាយរីករាយ ដែលបានប្រារព្ធពិធីចុះហត្ថលេខា សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន លើ ″គម្រោងលើកកម្ពស់ការអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ ក្នុងខេត្តកណ្តាល (ដំណាក់កាលទី3)″ ដល់អង្គការAARជប៉ុន។

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ជូនថវិកាប្រមាណជា US$280,000 ដល់អង្គការAARជប៉ុន។ អង្គការAARជប៉ុននេះ នឹងបន្តសកម្មភាពគាំទ្រដល់ការអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ ក្នុងខេត្តកណ្តាល ដើម្បីអោយកុមារទាំងអស់អាចរៀនជាមួយគ្នាដោយគ្មានការរើសអើង។ ជាក់ស្តែងអង្គការAARជប៉ុន នឹងលុបបំបាត់ឧបសគ្គនានាក្នុងការបំលាស់ទីក្នុងបរិវេណសាលារៀន និងបណ្តុះបណ្តាលដល់គ្រូបង្រៀន និងសហគមន៍ផងដែរ។ ខ្ញុំសង្ឃឹមថា គម្រោងនេះ នឹងជួយកែលម្អបរិស្ថានអប់រំសម្រាប់កុមារពិការ ដើម្បីរួមចំណែកបង្កើនអត្រាចូលរៀនរបស់កុមារពិការនៅសាលាបឋមសិក្សាចំនួន4 ក្នុងស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

ជាចុងក្រោយនេះ ជំនួយឧបត្ថម្ភរបស់ជប៉ុន សម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន ត្រូវបានផ្តល់ជូនសម្រាប់គម្រោងអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនដែលរស់នៅតាមកម្រិតមូលដ្ឋាន។ ខ្ញុំសង្ឃឹមថា គម្រោងនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រទេសជប៉ុន និងប្រទេសកម្ពុជា៕

សូមអរគុណ!